**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៣៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៧ ដែលប្រកាស អោយប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- យោងតាមការចាំបាច់

## ស ម្រេ ច

**ប្រការ១ :** ត្រូវបានបង្កើតគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួង សាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| ៣- រដ្ឋមន្ត្រី ក្រសួង យុត្តិធម៌ | សមាជិក |
| ៤- រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ៦- អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៧- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៨- អភិបាលរាជធានី-ខេត្ត | សមាជិក ។ |

**ប្រការ២ :** គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកមានភារកិច្ចដូចតទៅ :

- កសាងផែនការសកម្មភាព និងតាក់តែងលិខិតបទដ្ឋានគតិយុត្តិនានា សំដៅរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ កាត់បន្ថយការកកស្ទះ កាត់បន្ថយបទល្មើស និងអាត្រាគ្រោះថ្នាក់ចរាចរណ៍ ដើម្បីជំរុញការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកឱ្យមានប្រសិទ្ធភាព ។
- ប្រមូលផ្តុំចាត់ចែងកងកម្លាំងនគរបាលជាតិ កងរាជអាវុធហត្ថ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ដើម្បីអនុវត្តឱ្យបានម៉ឺងម៉ាត់មានប្រសិទ្ធភាព និងជាប់ជាប្រចាំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។
- ជំរុញការឃោសនាអប់រំ ផ្សព្វផ្សាយព័ត៌មាន គោលការណ៍ វិធានការផ្សេងៗជូនដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត និងប្រជាពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់ ជ្រួតជ្រាប និងគោរពប្រតិបត្តិអោយបានម៉ឺងម៉ាត់ ហ្មត់ចត់ ត្រឹមត្រូវតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។
- កសាងពង្រឹងសមត្ថភាព គុណភាពមន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ព្រមទាំងលើកគម្រោងផែនការបំពាក់ឧបករណ៍ សម្ភារៈបច្ចេកទេស និងមធ្យោបាយ សំដៅបង្កើនប្រសិទ្ធភាពកិច្ចប្រតិបត្តិការបង្ការ ទប់ស្កាត់បង្ក្រាបបទល្មើសចរាចរណ៍ផ្លូវគោក ។
- ទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល និងប្រទេសជាដៃគូរសំដៅស្វែងរកការគាំទ្រមូលនិធិ ថវិកា សម្ភារៈបច្ចេកទេស និងការបណ្តុះបណ្តាល ។
- តាមដានត្រួតពិនិត្យ វាស់ស្ទង់ការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោករបស់មន្ត្រីអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃការគោរពច្បាប់ពីសំណាក់ប្រជាពលរដ្ឋទូទៅ ដើម្បីបូកសរុបដកពិសោធន៍ ដាក់ចេញផែនការ វិធានការកែលំអរអោយបានសមស្រប និងទាន់ពេលវេលា ។
- ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣ :** គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។

លេខាធិការដ្ឋាននេះមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៣- អគ្គស្នងការរងទទួលបន្ទុកផែនសណ្តាប់ធ្នាប់សាធារណៈ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៥- តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៦- តំណាងក្រសួងព័ត៌មាន | សមាជិក |
| ៧- តំណាងក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ៨- ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ | សមាជិក |
| ៩- ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់សាធារណៈ | សមាជិក |
| ១០-តំណាងអភិបាលរាជធានី ខេត្ត | សមាជិក ។ |

**ប្រការ៤ :** លេខាធិការដ្ឋានគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកមានភារកិច្ច ដូចទៅ :

- ជួយប្រធានគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ក្នុងការចាត់ចែងអនុវត្ត តាមដាន ត្រួតពិនិត្យ រំព្ញកដាស់តឿនបណ្តាភារកិច្ចដូចមានចែងក្នុងប្រការ ២ ។
- រៀបចំកម្មវិធីការងារ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការដឹកនាំបញ្ជាត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ។
- ចាត់ចែងកិច្ចការងាររដ្ឋបាល តាមការណែនាំរបស់ប្រធានគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ។
- ធ្វើរបាយការណ៍ជូនប្រធានគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ។
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលដឹកនាំរបស់ប្រធានគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក ។

**ប្រការ៥ :** គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកមានសិទ្ធិប្រើប្រាស់ថវិកា និងត្រារបស់ក្រសួងមហាផ្ទៃ ។

**ប្រការ៦ :** អភិបាលរាជធានី ខេត្តនានា ត្រូវបង្កើតគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍នៅថ្នាក់រាជធានី ខេត្តរបស់ខ្លួន ដោយមានអភិបាលរាជធានី ខេត្ត ធ្វើជាប្រធាន និងមានសមាសភាពប្រធានមន្ទីរ អង្គភាព ដូចនៅថ្នាក់ជាតិ ។

**ប្រការ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អភិបាលរាជធានី ខេត្ត និងសមាសភាពដូចមានចែងក្នុងប្រការ ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០០៩

**ស ខេង**

***កន្លែងទទួល:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៧*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*